# សន្និបាតបូកសរុប
# លទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការងារ
# ឆ្នាំ២០២៤ របស់ក្រសួងផែនការ

## របាយការណ៍សង្ខេប
## លទ្ធផលសំខាន់ៗដែលសម្រេចបានឆ្នាំ២០២៣
## និងទិសដៅការងារឆ្នាំ២០២៤
## របស់វិទ្យាស្ថានជាតិស្ថិតិ

នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

# មាតិកា

## I. សេចក្តីផ្តើម

១. ប្រវត្តិ

២. រចនាសម្ព័ន្ធ

៣. តួនាទី និងភារកិច្ច

៤. ទស្សនវិស័យ និងបេសកកម្ម

៥. គោលដៅ

៦. ច្បាប់ និងបទបញ្ញត្តិស្ថិតិ

៥. សម្របសម្រួល និងសហប្រតិបត្តិការស្ថិតិ

## II. សកម្មភាព និងសមិទ្ធផលការងារសម្រេចបាន ឆ្នាំ២០២៣

១. ការពង្រឹងសមត្ថភាពមន្ត្រី

២. ការងារជំរឿន និងអង្កេត

# មាតិកា (ត)

៣. ការងារគណនេយ្យជាតិ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

៤. ការគ្រប់គ្រងទិន្នន័យ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយ

**III. បញ្ហាប្រឈម**

**IV. ទិសដៅការងារបន្ត**

**V. សន្និដ្ឋាន**

# I. សេចក្តីផ្តើម

## ១. ប្រវត្តិ

- នៅក្នុងយុគសម័យទំនើប សកម្មភាពស្ថិតិចាប់ផ្តើមនៅពេលដែលប្រទេសកម្ពុជាស្ថិតក្រោមអាណាព្យាបាលបារាំងក្នុងឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ រហូតដល់ឆ្នាំ១៩៤៨ នាយកដ្ឋានបានបង្កើតឡើងដាច់ដោយឡែកជាមជ្ឈមណ្ឌលស្ថិតិថ្នាក់កណ្តាលមានឈ្មោះថា **នាយកដ្ឋានស្ថិតិនៃកម្ពុជា** ចាប់តាំងពីពេលនោះមកនាយកដ្ឋានបានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន ដោយសារស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសង្គម។ ឈ្មោះ តួនាទី និងសកម្មភាពរបស់នាយកដ្ឋាននេះបានផ្លាស់ប្តូរជាហូរហែទៅតាមពេលវេលា
- ឆ្នាំ១៩៤៩ ដល់ឆ្នាំ១៩៥៣ មានឈ្មោះថា **នាយកដ្ឋានស្ថិតិនៃកម្ពុជា**
- ឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៦៣ ឈ្មោះថា **នាយកដ្ឋានស្ថិតិ និងពិនិត្យសេដ្ឋកិច្ច**
- ឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៧៥ ឈ្មោះថា **វិទ្យាស្ថានជាតិស្ថិតិ និងការស្រាវជ្រាវសេដ្ឋកិច្ច**
- ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រព័ន្ធស្ថិតិជាតិកម្ពុជាត្រូវលុបបំបាត់ចោលទាំងស្រុង។
- ឆ្នាំ១៩៧៩ **នាយកដ្ឋានស្ថិតិ** ត្រូវបានបង្កើតឡើងវិញ ស្ថិតនៅក្រោមឱវាទក្រសួងហិរញ្ញវត្ថុ។ ឆ្នាំ១៩៨១ **នាយកដ្ឋានស្ថិតិ** ត្រូវបានផ្ទេរមកក្រសួងផែនការវិញ។
- ឆ្នាំ១៩៩៤ ត្រូវបានប្តូរឈ្មោះទៅជា **វិទ្យាស្ថានជាតិស្ថិតិ** ស្មើអគ្គនាយកដ្ឋាន
- ឆ្នាំ២០០៥ មកដល់បច្ចុប្បន្នបានប្តូរឈ្មោះ **វិទ្យាស្ថានជាតិស្ថិតិ**

## ២. ស្ថានភាពមន្ត្រីរាជការ និងរចនាសម្ព័ន្ធ

**វិទ្យាស្ថានជាតិស្ថិតិ** មានមន្ត្រីរាជការសរុបចំនួន ៤៩៨នាក់ ក្នុងនោះប្រុសមានចំនួន ៣១៣នាក់ និងស្រីមានចំនួន ១៨៥នាក់។ វិទ្យាស្ថានជាតិស្ថិតិមាន នាយកដ្ឋានជំនាញចំនួន ១០ ដូចខាងក្រោម៖

១. នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ (មាន៥ការិយាល័យ)
២.នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច (មាន៤ការិយាល័យ)
៣.នាយកដ្ឋានស្ថិតិសង្គមកិច្ច (មាន៤ការិយាល័យ)
៤. នាយកដ្ឋានស្ថិតិប្រជាសាស្រ្តជំរឿន និងអង្កេត (មាន៥ការិយាល័យ)
៥. នាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ (មាន៤ការិយាល័យ)
៦. នាយកដ្ឋានគ្រប់គ្រងទិន្នន័យ អភិវឌ្ឍន៍កម្មវិធី និងបច្ចេកវិទ្យា (មាន៥ការិយាល័យ)
៧. នាយកដ្ឋានគណនេយ្យជាតិ (មាន៦ការិយាល័យ)
៨. នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ (មាន៤ការិយាល័យ)
៩. នាយកដ្ឋានស្ថិតិវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ (មាន៥ការិយាល័យ)
១០. នាយកដ្ឋានសេវាព័ត៌មានស្ថិតិ (មាន៥ការិយាល័យ)។


ក្រសួងផែនការ
ក្រុមប្រឹក្សាស្ថិតិ
អគ្គនាយក
គណៈកម្មាធិការសម្របសម្រួលស្ថិតិ
អគ្គនាយករង
នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ
ការិយាល័យរដ្ឋបាល
ការិយាល័យសហប្រតិបត្តិការស្ថិតិ
ការិយាល័យផែនការ កម្មវិធីស្ថិតិ
ការិយាល័យគោលនយោបាយ និងបទប្បញ្ញត្តិស្ថិតិ
ការិយាល័យធនធានមនុស្ស និងប្រព័ន្ធទិន្នន័យមូលដ្ឋានខេមស្តាត
នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច
ការិយាល័យស្ថិតិកសិកម្ម
ការិយាល័យស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម
ការិយាល័យស្ថិតិសំណង់ ទេសចរណ៍ បរិស្ថាន និងគមនាគមន៍
ការិយាល័យសរុប និងវិភាគស្ថិតិសេដ្ឋកិច្ច
នាយកដ្ឋានស្ថិតិសង្គមកិច្ច
ការិយាល័យស្ថិតិអប់រំ យុវជន និងកីឡា
ការិយាល័យស្ថិតិសង្គមកិច្ច និងការងារ
ការិយាល័យស្ថិតិសុខាភិបាល វប្បធម៌ ព័ត៌មាន និងសាសនា
ការិយាល័យសរុប និងវិភាគស្ថិតិសង្គមកិច្ច
នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត
ការិយាល័យស្ថិតិប្រជាសាស្ត្រ
ការិយាល័យជំរឿន
ការិយាល័យអង្កេត
ការិយាល័យប្រតិបត្តិការមូលដ្ឋាន
ការិយាល័យស្ថិតិអត្រានុកូលដ្ឋាន
នាយកដ្ឋានគ្រប់គ្រងទិន្នន័យ អភិវឌ្ឍន៍កម្មវិធី និងបច្ចេកវិទ្យា
ការិយាល័យហេដ្ឋារចនាសម្ព័ន្ធអាយ ស៊ី ធី
ការិយាល័យគ្រប់គ្រងមូលដ្ឋានទិន្នន័យ
ការិយាល័យអភិវឌ្ឍន៍កម្មវិធី
ការិយាល័យកែច្នៃទិន្នន័យ
ការិយាល័យផែនទី និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
នាយកដ្ឋានស្តង់ដារ និងវិធីសាស្ត្រស្ថិតិ
ការិយាល័យចំណាត់ថ្នាក់ស្តង់ដារស្ថិតិ
ការិយាល័យវិធីសាស្ត្រស្ថិតិ
ការិយាល័យសម្របសម្រួលស្ថិតិ
ការិយាល័យសរុបវិភាគស្ថិតិ និងស្រាវជ្រាវ
នាយកដ្ឋានគណនេយ្យជាតិ
ការិយាល័យគណនីផលិតកម្ម
ការិយាល័យគណនីសមភាគចំណាយ
ការិយាល័យគណនីសមភាគចំណូល
ការិយាល័យសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់
ការិយាល័យសន្ទស្សន៍ថ្លៃអ្នកផលិត
ការិយាល័យសរុប និងវិភាគស្ថិតិម៉ាក្រូសេដ្ឋកិច្ច
នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ
ការិយាល័យសរុប និងវិភាគស្ថិតិថ្នាក់ក្រោមជាតិ
ការិយាល័យស្ថិតិប្រជាសាស្ត្រថ្នាក់ក្រោមជាតិ
ការិយាល័យស្ថិតិសេដ្ឋកិច្ចថ្នាក់ក្រោមជាតិ
ការិយាល័យស្ថិតិសង្គមកិច្ចថ្នាក់ក្រោមជាតិ
នាយកដ្ឋានស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ការិយាល័យអង្កេតអាជីវកម្មផ្នែកស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ការិយាល័យចងក្រងទិន្នន័យស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ការិយាល័យស្ថិតិរដ្ឋបាលផ្នែកស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ការិយាល័យសម្របសម្រួល និងសហប្រតិបត្តិការផ្នែកស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា
ការិយាល័យស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍
នាយកដ្ឋានសេវាព័ត៌មានស្ថិតិ
ការិយាល័យកម្រងស្ថិតិ និងបោះពុម្ព
ការិយាល័យសេវាកម្មអតិថិជន និងផ្សព្វផ្សាយ
ការិយាល័យសេវាប្រឹក្សា និងព័ត៌មាន
ការិយាល័យប្រតិបត្តិការទិន្នន័យធំ
ការិយាល័យសមាហរណកម្មទិន្នន័យ
មន្ទីរផែនការ រាជធានី ខេត្ត

# ៣. តួនាទី និងភារកិច្ច

**វិទ្យាស្ថានជាតិស្ថិតិ** គឺជាស្ថាប័នស្ថិតិជាតិផ្លូវការរបស់រាជរដ្ឋាភិបាល ស្ថិតក្រោមឱវាទក្រសួងផែនការ មានភារកិច្ចទទួលខុសត្រូវ ៖

១. ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។

២. ស្រាវជ្រាវ ចងក្រងវិធីសាស្ត្រផ្សេងៗ អភិវឌ្ឍម៉ូដែល និងបច្ចេកទេសស្ថិតិ ដើម្បីបង្កើនគុណភាពស្ថិតិផ្លូវការ។

៣. ធានាការសម្របសម្រួល ប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំង ក្នុងការប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ។

# ៣. តួនាទី និងភារកិច្ច (ត)

៤. រៀបចំគោលនយោបាយ និងបទដ្ឋានស្ថិតិសម្រាប់ការអនុវត្តឯកភាពគ្នា របស់អង្គភាពស្ថិតិដែលបានចាត់តាំង។

៥. ផ្តល់ការណែនាំ និងជួយគាំទ្រដល់អង្គភាពស្ថិតិដែលបានចាត់តាំង ទាក់ទងនឹងស្ថិតិផ្លូវការ។

៦. ទំនាក់ទំនងជាមួយបណ្តាប្រទេសនានា និងអង្គការអន្តរជាតិនានា ដែលទាក់ទងនឹងការងារស្ថិតិ។

# ៤. ទស្សនវិស័យ និងបេសកកម្ម

**ទស្សនវិស័យ** របស់វិទ្យាស្ថានជាតិស្ថិតិ គឺឈរលើមូលដ្ឋាននៃគោលការណ៍ ៥ យ៉ាង៖ភាពសំខាន់ សុច្ចរិតភាព ភាពអាចប្រើប្រាស់បាន វិជ្ជាជីវៈនិយម និងជំនឿចិត្ត។

**បេសកកម្ម** របស់វិទ្យាស្ថានជាតិស្ថិតិ គឺការសម្របសម្រួល ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការប្រកបដោយគុណភាពខ្ពស់ និងត្រូវគោលដៅ ដើម្បីជួយដល់ការធ្វើសេចក្ដីសម្រេចចិត្ត ការជជែកវែកញែក និងការពិភាក្សា ក្នុងរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់រាជធានី ខេត្ត និងឃុំ សង្កាត់ ធុរៈកិច្ច និងប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ។

# ៥. គោលដៅ

១. សម្របសម្រួល និងធ្វើឱ្យប្រសើរឡើងក្នុងប្រព័ន្ធស្ថិតិជាតិនៃព្រះរាជាណាចក្រកម្ពុជា។

២. វិទ្យាស្ថានជាតិស្ថិតិផ្តល់សេវាកម្មស្ថិតិទាន់ពេលវេលា ការពាក់ព័ន្ធ ការឆ្លើយតប និងគោរពសុច្ចរិតភាព និងគុណភាព។

៣. ផ្តល់ព័ត៌មាន និងបង្កើនការប្រើប្រាស់ស្ថិតិផ្លូវការ។

៤. ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពស្ថិតិអន្តរជាតិ ដែលមានសារៈសំខាន់ដល់ព្រះរាជាណាចក្រកម្ពុជា និងតំបន់។

៥. ជាស្ថាប័នដែលលើកទឹកចិត្តដល់ការសិក្សាស្វែងយល់ ច្នៃប្រឌិត និងអនុវត្តខ្ពស់ក្នុងគ្រប់សកម្មភាព និងការអភិវឌ្ឍស្ថិតិ។

៦. មានជំនឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការ ក្នុងការផ្តល់ទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ។

៧. មានការទទួលស្គាល់ខ្ពស់ និងគាំទ្រដល់វិទ្យាស្ថានជាតិស្ថិតិ ពីសំណាក់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសហគមន៍ជាតិ និងអន្តរជាតិ។

# ៦. ច្បាប់ និងបទបញ្ញត្តិស្ថិតិ

-ច្បាប់ស្តីពីស្ថិតិឆ្នាំ២០០៥ ត្រូវបានធ្វើវិសោធនកម្ម និងចូលជាធរមានកាលពីថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៥

- អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ឆ្នាំ២០០៧ ត្រូវបានធ្វើវិសោធនកម្ម និងចូលជាធរមានថ្ងៃទី០៩ ខែកញ្ញាឆ្នាំ២០២១

-អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងឆ្នាំ២០១០ ត្រូវបានធ្វើវិសោធនកម្ម និងចូលជាធរមានថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១

# ៦. ច្បាប់ និងបទបញ្ញត្តិស្ថិតិ(ត)

យោងតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ

- **ក្រុមប្រឹក្សាស្ថិតិ** ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលប្រព័ន្ធស្ថិតិជាតិកម្ពុជា ដោយមានរដ្ឋមន្ត្រីក្រសួងផែនការជាប្រធាន ហើយរដ្ឋលេខាធិការ ក្រសួង ស្ថាប័ន និងផ្នែកឯកជនមួយចំនួនជាសមាជិក ត្រូវប្រជុំការងារយ៉ាងតិចពីរដងក្នុងមួយឆ្នាំ។
- **គណៈកម្មាធិការសម្របសម្រួលស្ថិតិ** អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិជាប្រធាន និងមានប្រធាននាយកដ្ឋានក្រសួង ស្ថាប័ន ជាសមាជិក ត្រូវប្រជុំការងារយ៉ាងតិចពីរដងក្នុងមួយឆ្នាំ។
- **អនុក្រុមការងារទិន្នន័យសម្រាប់អភិវឌ្ឍន៍ នៃក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ** ដែលមានអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងប្រធានមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនប្រចាំកម្ពុជា ជា**សហប្រធាន** ដឹកនាំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលនៅព្រះរាជាណាចក្រកម្ពុជាមួយចំនួន និងប្រធានអង្គភាពស្ថិតិនៃក្រសួង ស្ថាប័ន មួយចំនួនជារៀងរាល់បីខែម្តង។

# ៦. ច្បាប់ និងបទបញ្ញត្តិស្ថិតិ(ត)

ការងារជំរឿន និងអង្កេត ដែលសម្រេចបានក្នុងផែនការមេស្ថិតិ(SMP) ឆ្នាំ២០០៧-២០១៥ រួមមាន៖

- ជំរឿនប្រជាជនឆ្នាំ២០០៨ (UNFPA រដ្ឋាភិបាលជប៉ុន JICA រដ្ឋាភិបាលអាល្លឺម៉ង់ និងរដ្ឋាភិបាលកម្ពុជា)
- អង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០១៤ ( រាជរដ្ឋាភិបាលកម្ពុជា UNFPA រដ្ឋាភិបាលជប៉ុន JICA និងរដ្ឋាភិបាលអាល្លឺម៉ង់)
- ជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ ( រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន និងJICA)
- អង្កេតចន្លោះជំរឿនសេដ្ឋកិច្ចឆ្នាំ២០១៤( រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន និងJICA)
- ជំរឿនកសិកម្មឆ្នាំ២០១៣ ( រដ្ឋាភិបាលកម្ពុជា FAO Sweden Severige Autrallian Aid USAID)
- អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES)ប្រចាំឆ្នាំ២០០៧ដល់ឆ្នាំ២០១៧ (រាជរដ្ឋាភិបាលកម្ពុជា និងSida)
- អង្កេតប្រជាសាស្រ្ត និងសុខភាពកម្ពុជា(CDHS) ឆ្នាំ២០១០ និង២០១៤(រដ្ឋាភិបាលកម្ពុជា UNFPA USAID HSSP-2 UNICEF និងJICA)
- អង្កេតកំលាំងពលកម្មឆ្នាំ២០១១ ( ILO និងរដ្ឋាភិបាលកម្ពុជា)

# ៦. ច្បាប់ និងបទបញ្ញត្តិស្ថិតិ (ត)

ការងារជំរឿន និងអង្កេតដែលសម្រេចបានក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ឆ្នាំ២០១៩-២០២៣ រួមមាន៖

- ជំរឿនប្រជាជនឆ្នាំ២០១៩ (រាជរដ្ឋាភិបាលកម្ពុជា UNFPA CHINA AID រដ្ឋាភិបាលអាល្លឺម៉ង់ EU និង Sweden Sverige)
- ជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ (រាជរដ្ឋាភិបាលកម្ពុជា Australian Aid និងWB GROUP)
- ជំរឿនកសិកម្មឆ្នាំ២០២៣ (រដ្ឋាភិបាលកម្ពុជា និងFAO គាំទ្រខាងបច្ចេកទេស)
- អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) រៀងរាល់ពីរឆ្នាំម្តង ឆ្នាំ២០១៩ ឆ្នាំ២០២១ និងឆ្នាំ២០២៣ (រាជរដ្ឋាភិបាលកម្ពុជា)
- អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០២១-២០២២ (រដ្ឋាភិបាលកម្ពុជា UNFPA USAID HSSP-2 UNICEF និងJICA)
- អង្កេតកំលាំងពលកម្មឆ្នាំ២០១៩ (រាជរដ្ឋាភិបាលកម្ពុជា ADB និងILO)

# II.សកម្មភាព និងសមិទ្ធផលការងារសម្រេចបាន ឆ្នាំ២០២៣ (ត)

## ១. ការពង្រឹងសមត្ថភាពមន្ត្រី

- បានបញ្ជូនមន្ត្រី ៤រូប ទៅរៀនសាលាភូមិន្ទរដ្ឋបាល(ERA) ឆ្នាំ២០២៣
- បានបញ្ជូនមន្ត្រី ២៣រូប ទៅរៀនសាលាជាតិផែនការ និងស្ថិតិ ឆ្នាំ២០២៣ និងឆ្នាំ២០២៤
- បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ តាមមន្ទីរផែនការ លើជំនាញការវិភាគស្ថិតិតាមតំបន់ដោយប្រើប្រាស់កម្មវិធី SPSS ការផលិតផែនទីស្ថិតិដោយប្រើប្រាស់កម្មវិធី GIS វិធីសាស្ត្រ វិភាគ និងសរសេររបាយការណ៍ស្ថិតិតាមតំបន់ ការវិភាគស្ថិតិសុខាភិបាល និងស្ថិតិអប់រំ ដោយប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច។

## II.សកម្មភាព និងសមិទ្ធផលការងារសម្រេចបាននៅឆ្នាំ២០២៣ (ត)

### ១. ការពង្រឹងសមត្ថភាពមន្ត្រី (ត)

- បានចូលរួមសម័យប្រជុំលើកទី៥៥ របស់គណៈកម្មាធិការស្ថិតិនៃអង្គការសហប្រជាជាតិ
- បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន និងក្រុមការងារបច្ចេកទេស ព្រមទាំងបានផ្តល់ទិន្នន័យផ្សេងៗជូនលេខាធិការដ្ឋានស្ថិតិអាស៊ាន
- ដៃគូអភិវឌ្ឍន៍មួយចំនួនបានគាំទ្រ និងសហការជាមួយវិទ្យាស្ថានជាតិស្ថិតិក្នុងការផលិតស្ថិតិ និងការកសាងសមត្ថភាព ក្នុងនោះរួមមាន៖ អង្គការ UNFPA, UNICEF, UNDP, UN Women, FAO, WB, EU, ADB, ILO, Asai Foundation, Vital Strategies, WaterAid និងអង្គការ ODC ជាដើម។

## ២. ការងារជំរឿន និងអង្កេត

- ដឹកនាំការធ្វើជំរឿនកសិកម្មនៅកម្ពុជា ឆ្នាំ២០២៣
- ផ្សព្វផ្សាយលទ្ធផលជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២
- ដឹកនាំអង្កេតកសិកម្មនៅកម្ពុជា ប្រចាំឆ្នាំ២០២៣
- ដឹកនាំអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៣
- ដឹកនាំអង្កេតនវានុវត្តន៍សម្រាប់ខេត្តបន្ទាយមានជ័យ កំពង់ចាម និង ខេត្តស្វាយរៀង ឆ្នាំ២០២៣
- ដឹកនាំអង្កេតភពផែនដី នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣ សម្រាប់ ខេត្តកំពត និងខេត្តកែប
- ដឹកនាំអង្កេតស្តីពីការពិនិត្យបង្គន់អនាម័យ ឆ្នាំ២០២៣

# II.សកម្មភាព និងសមិទ្ធផលការងារសម្រេចបាននៅឆ្នាំ២០២៣ (ត)

## ៣. ការងារគណនេយ្យជាតិ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

### ៣.១. ការងារគណនេយ្យជាតិ

- ចុះប្រមូលទិន្នន័យតាមក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល (ទិន្នន័យកសិកម្ម សំណង់ អគ្គិសនី ទឹកស្អាត នាំចេញនាំចូល)
- គណនាតម្លៃបន្ថែមវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម តាមវិធិសាស្រ្ត ផលិតកម្ម និងវិធិសាស្រ្តចំណាយសម្រាប់ឆ្នាំ២០២៣
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់លទ្ធផលនៃការផ្លាស់ប្តូរឆ្នាំគោល គណនេយ្យជាតិឆ្នាំ២០១៤
- រៀបចំវគ្គបណ្តុះបណ្តាលស្ថិតិគណនេយ្យជាតិដល់មន្រ្តីមន្ទីរផែនការតាម បណ្តាខេត្តដូចជា៖ ខេត្តព្រៃវែង មណ្ឌលគិរី ប៉ៃលិន សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ បាត់ដំបង និងខេត្តក្រចេះ។

## II.សកម្មភាព និងសមិទ្ធផលការងារសម្រេចបាននៅឆ្នាំ២០២៣ (ត)

### ៣.២. ការងារសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

- បានចុះប្រមូលទិន្នន័យ ថ្លៃទំនិញប្រើប្រាស់ ពីផ្សារទាំង៥ (ផ្សារធំថ្មី, ផ្សារអូរឫស្សី ផ្សារដើមគរ ផ្សារទួលទំពូង និងផ្សារច្បារអំពៅ) សម្រាប់គណនារកសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ជាប្រចាំខែសម្រាប់រាជធានីភ្នំពេញ
- ធ្វើរបាយការណ៍សង្ខេបអតិផរណាថ្លៃទំនិញប្រើប្រាស់ជាប្រចាំខែសម្រាប់រាជធានីភ្នំពេញ
- ជួយត្រួតពិនិត្យការប្រមូលទិន្នន័យថ្លៃទំនិញប្រើប្រាស់ និងគណនាសន្ទស្សន៍ថ្លៃ តាមប្រព័ន្ធ (CPI TOOL) ថ្នាក់ខេត្ត មានដូចជា៖ ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ សៀមរាប តាកែវ ឧត្តរមានជ័យ កែប និងខេត្តត្បូងឃ្មុំ
- រៀបចំបើកវគ្គបណ្តុះបណ្តាលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ដល់មន្ត្រីមន្ទីរផែនការតាមបណ្តាខេត្តដូចជា៖ ខេត្តមណ្ឌលគិរី ប៉ៃលិន ព្រៃវែង ក្រចេះ ឧត្តរមានជ័យ ព្រះសីហនុ សៀមរាប និងខេត្តបន្ទាយមានជ័យ។

## ៤. ការគ្រប់គ្រងទិន្នន័យ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយ

- ប្រមូលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិចំនួន ២ខេត្ត (ខេត្តប៉ៃលិន និងខេត្តសៀមរាប) ព្រមទាំងបានផ្សព្វផ្សាយរបាយការណ៍លទ្ធផល តាមរយៈវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ
- បានធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា និងចំណាត់ថ្នាក់ស្តង់ដារមុខរបរកម្ពុជា
- បានធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ស្តង់ដារកម្ពុជា ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បានប្រមូល ចងក្រងព័ត៌មានបឋម និងវិភាគព័ត៌មានស្ថិតិកសិកម្ម រុក្ខកម្ម នេសាទ ស្ថិតិចំណូល ចំណាយ និងបំណុលរបស់គ្រួសារ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម និងវិនិយោគ ស្ថិតិសំណង់ ស្ថិតិទូរគមនាគមន៍ ដឹកជញ្ជូន ស្ថិតិទេសចរណ៍ ស្ថិតិបរិស្ថានសម្រាប់ឆ្នាំ២០២៣

# II.សកម្មភាព និងសមិទ្ធផលការងារសម្រេចបានឆ្នាំ២០២៣ (ត)

## ៤. ការគ្រប់គ្រងទិន្នន័យ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយ (ត)

- បានប្រមូលចងក្រង វិភាគ ផ្សព្វផ្សាយទិន្នន័យស្ថិតិទំនិញពាណិជ្ជកម្មអន្តរជាតិប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ២០២៣
- ប្រមូលទិន្នន័យតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធនានាសម្រាប់ការងារចងក្រងសៀវភៅកម្រងទិន្នន័យស្ថិតិប្រចាំឆ្នាំ (Statistical Year Book)
- ប្រមូល ចងក្រង និងវិភាគដើម្បីរៀបចំជាសៀវភៅកម្រងទិន្នន័យស្ថិតិសង្គមកិច្ចប្រចាំឆ្នាំ
- របាយការណ៍វិភាគស៊ីជម្រៅដោយប្រើប្រាស់ទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០២១/២០២២ លើប្រធានបទ៖ អំពើហិង្សាក្នុងគ្រួសារ អត្រាមរណភាពមាតា និងទារក និងលទ្ធភាពបង្កកំណើត

## II.សកម្មភាព និងសមិទ្ធផលការងារសម្រេចបានឆ្នាំ២០២៣ (ត)

### ៤. ការគ្រប់គ្រងទិន្នន័យ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយ (ត)

- ការផលិតផែនទីសូចនាករយេនឌ័រ ដោយប្រើប្រាស់ទិន្នន័យជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ និងជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២
- គ្រប់គ្រង និងថែរក្សាទិន្នន័យជំរឿន និងអង្កេតដែលមានក្នុង Server និងប្រព័ន្ធ Database ព្រមទាំងបច្ចុប្បន្នភាពទិន្នន័យទៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ
- ជំរុញការប្រើប្រាស់ប្រភពទិន្នន័យធំ ដើម្បីផលិតស្ថិតិផ្លូវការនៅកម្ពុជា៖ បានចូលរួមគម្រោងសាកល្បងស្តីពីការប្រើប្រាស់ប្រភពទិន្នន័យធំចំនួន២៖ (១ ការប្រើប្រាស់ប្រភពទិន្នន័យធំ ដើម្បីផលិតស្ថិតិផ្នែកទេសចរណ៍ សូចនាករចំនួនប្រើប្រាស់បន្ទប់របស់សណ្ឋាគារ ផ្ទះសំណាក់។ល។) និង(២ ការប្រើប្រាស់ប្រភពទិន្នន័យធំ ដើម្បីផលិតសូចនាករ ការប្រើប្រាស់ប្រភពបំភ្លឺ)
- បច្ចុប្បន្នភាពទិន្នន័យសូចនាករចេញពីជំរឿន អង្កេត និងទិន្នន័យរដ្ឋបាល ទៅក្នុងថ្នាលទិន្នន័យរាយការណ៍សូចនាករជាតិកម្ពុជា (CAMSTAT)។

## II. បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបានការងារសំខាន់ៗ វិទ្យាស្ថានជាតិស្ថិតិក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- សមត្ថភាពមន្ត្រីមួយចំនួននៅមានកម្រិត លើជំនាញវិភាគទិន្នន័យជំរឿន និងអង្កេត ព្រមទាំងការរៀបចំឯកសារតាមនីតិវិធីបែបបទរដ្ឋបាល
- ការចែករំលែកទិន្នន័យរដ្ឋបាល និងអង្កេតនានាពីក្រសួង ស្ថាប័ននៅមានកម្រិតនៅឡើយ
- មិនមានដៃគូអភិវឌ្ឍន៍ជួយគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុទៅលើអង្កេតមួយចំនួនដូចជា អង្កេតថ្នាក់ជាតិស្ដីពីការស្រាវជ្រាវនិងអភិវឌ្ឍន៍ ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងអង្កេតថ្នាក់ជាតិស្ដីពីនវានុវត្តន៍
- ការទទួលបានថវិកាពីរាជរដ្ឋាភិបាលនៅមានកម្រិតនៅឡើយ ដោយអង្កេតមួយចំនួនមិនមានថវិកាសម្រាប់ផលិត មានដូចជាអង្កេតថ្នាក់ជាតិស្ដីពីការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា អង្កេតថ្នាក់ជាតិស្ដីពីនវានុវត្តន៍ អង្កេតកម្លាំងពលកម្មប្រចាំឆ្នាំ ដែលអង្កេតកម្លាំងពលកម្មចុងក្រោយនៅក្នុងឆ្នាំ២០១៩

# II. បញ្ហាប្រឈម (ត)

- ខ្វះខាតសម្ភារៈការិយាល័យមួយចំនួនដូចជា ក្រដាស ទឹកថ្នាំម៉ាស៊ីនព្រីន និងទឹកថ្នាំម៉ាស៊ីនថតចម្លង
- គ្រឿងបរិក្ខារដូចជា តុ កៅអីមួយចំនួនបានបាក់បែក និងរបកស្បែក កុំព្យូទ័រមួយចំនួនខូចលែងដំណើរការ និងម៉ាស៊ីនត្រជាក់មួយចំនួនលែងត្រជាក់...
- បន្ទប់ការិយាល័យរបស់នាយកដ្ឋាននីមួយៗមានលក្ខណៈតូចចង្អៀត។

## IV. ទិសដៅការងារឆ្នាំ២០២៤

- រៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ឆ្នាំ២០២៤-២០២៨
- ការអនុវត្តន៍គម្រោង EU Twining ដោយផ្តោតលើការលើកកម្ពស់គុណភាពនៃប្រព័ន្ធស្ថិតិជាតិកម្ពុជា ដែលគាំទ្រដោយ EU
- បណ្តុះបណ្តាលមន្ត្រីតាមមន្ទីររាជធានី ខេត្ត ក្នុងការវិភាគតារាងទិន្នន័យ និងរបាយការណ៍លទ្ធផលនៃជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២
- ផ្សព្វផ្សាយរបាយការណ៍លទ្ធផលជំរឿនកសិកម្ម ឆ្នាំ២០២៣
- ដឹកនាំអង្កេតចន្លោះជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៤
- ដឹកនាំអង្កេតកសិកម្មកម្ពុជា ប្រចាំឆ្នាំ២០២៤
- ដឹកនាំអង្កេតនវានុវត្តន៍នៅ ខេត្តកំពត កោះកុង និងខេត្តកែប ឆ្នាំ២០២៤
- ផ្សព្វផ្សាយលទ្ធផលអង្កេតនវានុវត្តន៍នៅ រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ ឆ្នាំ២០២២

# IV. ទិសដៅការងារឆ្នាំ២០២៤ (ត)

- ប្រមូលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ឆ្នាំ២០២៤ ចំនួន ២ខេត្ត រួមមាន ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ចុះប្រមូលទិន្នន័យតាមបណ្តាក្រសួងមន្ទីរពាក់ព័ន្ធនានា និងគណនាគណនេយ្យជាតិ ប្រចាំឆ្នាំ២០២៣
- បន្តការគណនាតម្លៃបន្ថែមវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម តាមវិធីសាស្ត្រផលិតកម្ម និងវិធីសាស្ត្រចំណាយ សម្រាប់ឆ្នាំ២០២៣
- គណនាតម្លៃបន្ថែមវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម តាមវិធីសាស្ត្រផលិតកម្ម និងវិធីសាស្ត្រចំណាយសម្រាប់ត្រីមាស ឆ្នាំ២០២៤
- ចុះពិភាក្សា និងពិគ្រោះយោបល់ការប្រមូលទិន្នន័យសម្រាប់ចងក្រងផលិតផលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០២៣-២០២៤
- បន្តប្រមូលទិន្នន័យថ្លៃទំនិញប្រើប្រាស់ពីផ្សារទាំង៥ (ផ្សារធំថ្មី ផ្សារអូរឫស្សី ផ្សារដើមគរ ផ្សារទួលទំពូង និងផ្សារច្បារអំពៅ) និងគណនាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សម្រាប់ខែនីមួយៗក្នុងឆ្នាំ២០២៤ សម្រាប់រាជធានីភ្នំពេញ

## IV. ទិសដៅការងារឆ្នាំ២០២៤ (ត)

- ធ្វើការចុះបញ្ជី និងគូសផែនទីតូបផ្សារ នៅក្នុងខណ្ឌឫស្សីកែវ និងខណ្ឌពោធិ៍សែនជ័យ
- បន្តផ្លាស់ប្តូរឆ្នាំគោល សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ពីឆ្នាំ២០០៦ ទៅឆ្នាំ២០១៩
- ប្រមូលថ្លៃអ្នកផលិតតាមរោងចក្រ សហគ្រាស ខ្នាតតូច ខ្នាតមធ្យម និងខ្នាតធំ ប្រចាំត្រីមាស
- កំណត់យក Frame ថ្មី ដើម្បីជ្រើសរើសសំណាកគំរូថ្មី
- ពង្រីកការប្រមូលទិន្នន័យសន្ទស្សន៍ថ្លៃអ្នកផលិតឱ្យបានទូទាំងប្រទេស
- ជំរុញការប្រើប្រាស់ប្រភពទិន្នន័យធំ ដើម្បីផលិតស្ថិតិផ្លូវការ និងសម្រាប់ SDG ព្រមទាំងជំរុញការប្រើប្រាស់ថ្នាលទិន្នន័យសុខាភិបាល ថ្នាលទិន្នន័យ Open SDG
- ជំរុញការផលិត Infographic សម្រាប់ផ្សព្វផ្សាយស្ថិតិផ្លូវការតាមរយៈប្រព័ន្ធបណ្តាញសង្គម។

# សូមអរគុណ!